ACT
Alliance for Conflict Transformation Organization

# ការសិក្សាស្រាវជ្រាវស្តីពី

# ស្ថានភាព និងផលប៉ះពាល់ នៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ក្នុងកំឡុងពេលនៃការរីករាលដាល ជំងឺកូវីដ១៩

ចាប់ពីថ្ងៃទី០១ ខែមករា ដល់ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២០

ឧបត្ថម្ភដោយ

Brot
Für die Welt

## អំពីអង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់

ក្រុមការងារដើម្បីដោះស្រាយទំនាស់(កដទ) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមិនរកប្រាក់កំរៃ មិនមាននិន្នាការនយោបាយ ឬចរិកសាសនាណាមួយឡើយ ហើយមានទីតាំងតែនៅ រាជធានីភ្នំពេញ។ **កដទ** បង្កើតឡើងដោយបុគ្គលដែលមានឆន្ទៈក្នុងការធ្វើការងារជាមួយគ្នាដើម្បីផ្តល់ជំនាញនិងចំណេះដឹង ក្នុងវិស័យនៃការដោះស្រាយទំនាស់ ការបំប្លែងទំនាស់ និងការកសាងសន្តិភាព។ **កដទ** ផ្តោតសំខាន់ទៅលើ ការកសាង និងពង្រឹងសមត្ថភាពផ្នែកសន្តិភាព ដោយយកការវិភាគស្ថានភាពនាពេលបច្ចុប្បន្ន ក្នុងការស្វែង សកម្មភាព ជាយុទ្ធសាស្រ្ត ដើម្បីឆ្លើយតបទៅនឹងបញ្ហាទំនាស់ ឆ្ពោះទៅរកសន្តិភាពនិងការអភិវឌ្ឍចីរភាព។ នៅក្នុងឆ្នាំ២០០២ **កដទ** បាន ចុះឈ្មោះ និងទទួលស្គាល់ដោយក្រសួងមហាផ្ទៃ ក្រោយពីបានផ្តល់វគ្គបណ្តុះ បណ្តាល សន្តិភាពមួយចំនួនទៅដល់ក្រុមគោលដៅ។

## អំពីការស្ទង់មតិ

ការចងក្រងអំពីការស្ទង់មតិនៃគម្រោងប្រព័ន្ធផ្សព្វផ្សាយដើម្បីសន្តិភាព ដើម្បីជាការស្វែងរកនៅធាតុ ចូលបន្ថែមទៅក្នុងគម្រោង និងដើម្បីស្វែងរកនូវការខ្វះខាតនៅចំនុចណាមួយក្នុងគម្រោង ដើម្បីធ្វើការ បំពេញបន្ថែមទៅលើចំនុចទាំងអស់នោះ និងធ្វើការស្ទង់ពីមតិយោបល់របស់អ្នកសារព័ត៌មាន ព្រមទាំង ប្រជាពលរដ្ឋអំពីការតាមដាននៅព័ត៌មាននិងចំណង់ចំណូលចិត្តទៅលើប្រព័ន្ធផ្សព្វផ្សាយ ឬការជឿទុកចិត្ត ទៅលើប្រព័ន្ធផ្សព្វផ្សាយនាពេលបច្ចុប្បន្ន។ បន្ទាប់ពីបានតាមដាននិងប្រមូលនូវរឿងរ៉ាវមួយចំនួន ព្រម ទាំងរបាយការណ៍ផ្សេងៗទៀត មកចងក្រងទុកជាឯកសារសម្រាប់ការសិក្សាទៅថ្ងៃអនាគតដល់អ្នកជំនាន់ ក្រោយ និងប្រមូលរាល់ការយល់ឃើញរបស់អ្នកសារព័ត៌មាន និងអ្នកសារព័ត៌មានប្រជាពលរដ្ឋ និងបញ្ហា នានាដែលបានកើតឡើងចំពោះអ្នកសារព័ត៌មាន និងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយនានា ដើម្បីជាការស្នើ ដល់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធ ដើម្បីរកនៅដំណោះស្រាយណាមួយសមស្របទៅតាមគោល ការណ៍សន្តិភាពជាសកល។

## សេចក្តីថ្លែងអំណរអរគុណនិងអរព្រះគុណ

**កដទ** សូមថ្លែងអំណរអរគុណដល់សិក្ខាកាមក្នុងគម្រោងប្រព័ន្ធផ្សព្វផ្សាយដើម្បីសន្តិភាពជាច្រើនជំនាន់ បានចូលរួមផ្តល់ជាមតិយោបល់មួយចំនួនក្នុងការរៀបចំនៅបញ្ជីសំនួរ។ សូមថ្លែងអំណរអរគុណដល់បុគ្គលិក **កដទ** ដែលបានបញ្ចូលទិន្នន័យ និងធ្វើការបូកសរុបនូវរបាយការណ៍នេះ។

**កដទ** សង្ឃឹមថារបាយការណ៍ស្តីពី “**ស្ថានភាពនិងផលប៉ះពាល់នៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាក្នុងកំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩**” និងបានជាប្រយោជន៍សម្រាប់ការងារនិងការសិក្សានាពេលខាងមុខ។ ខ្លឹមសារនៅក្នុងរបាយការណ៍នេះគឺជាការទទួលខុសត្រូវរបស់ **កដទ** និងមិនឆ្លុះបញ្ចាំងពីទស្សនរបស់ម្ចាស់ជំនួយ និងដៃគូពាក់ព័ន្ធផ្សេងទៀតនោះទេ។

ជាចុងក្រោយសូមកោតសរសើរ និងថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ និងបុគ្គលិកអង្គការ ក្រុមការងារដើម្បីដោះស្រាយទំនាស់ទាំងអស់គ្នាដែលផ្តល់ជាកំលាំងស្មារតី និងបានចូលរួមចែករំលែកបទពិសោធន៍ និងចំណេះដឹងលើខ្លឹមសារមួយចំនួនដែលធ្វើអោយស្នាដៃនេះកាន់តែមានលក្ខណល្អប្រសើរឡើង។ សូម ប្រសិទ្ធិ ពរជ័យ សេរីបវរ ដល់លោក លោកស្រី អ្នកនាង កញ្ញា ទាំងអស់ឱ្យមានសុខភាពល្អ និងទទួលបាននូវ សុខសន្តិភាពជារៀងរហូតទៅ។

របាយការណ៍នេះចង់ក្រងឡើងដោយមានការឧបត្ថមនិងគាំទ្រដោយ អង្គការនំប៉ុងពិភពលោក។

## មតិត្រឡប់

ប្រសិនបើលោកអ្នកមានសំណួរ ឬត្រូវការព័ត៌មានបន្ថែមអំពីរបាយការណ៍នេះ ឬមានបំណងចង់ផ្តល់មតិត្រឡប់ សូមទំនាក់ទំនងមក កដទ តាមរយៈ act@act.org.kh

# មាតិកា

**អំពីអង្គការក្រុមការងារដើម្បីដោះស្រាយទំនាស់**

**អំពីការស្ទង់មតិ**

សេចក្តីថ្លែងអំណរអរគុណនិងអរព្រះគុណ

I. **សេចក្តីផ្តើម**......១

II. **លទ្ធផលដែលបានប្រមូលតាមអនឡាញ**......៣

១. ចំនួនអ្នកចូលរួមផ្តល់បទសម្ភាស......៣

២. តួនាទីអ្នកដែលបានផ្តល់បទសម្ភាស......៤

៣. ចំនួនអ្នកតាមដានព័ត៌មាន......៤

៤. ប្រភេទព័ត៌មានដែលចូលចិត្តតាមដាន......៥

៥. ប្រភេទផ្តល់ព័ត៌មានដែលទទួលបានការតាមដានច្រើន......៦

៦. ប្រព័ន្ធផ្សព្វផ្សាយដែលទទួលបានការគាំទ្រច្រើន......៦

៧. ប្រភពផ្តល់ព័ត៌មានដែលជឿទុកចិត្ត......៧

៨. ការជឿទុកចិត្តទៅលើប្រព័ន្ធផ្សព្វផ្សាយ......៨

៩. បញ្ហាប្រឈមរបស់ប្រព័ន្ធផ្សព្វផ្សាយ......៨

១០. បញ្ហាប្រឈមរបស់អ្នកសារព័ត៌មាន......១០

១១. ផលប៉ះពាល់ដល់អ្នកសារព័ត៌មាននិងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម......១១

**សន្និដ្ឋាននិងអនុសាសន៍**

សេចក្តីសន្និដ្ឋាន......១៣

អនុសាសន៍......១៤

ឯកសារយោង

## □. សេចក្តីផ្តើម

មានការកើតឡើងនៅមេរោគដែលរីករាលដាលពីក្នុងខេត្តវូហាន(Wuhan) នៃប្រទេសចិន។ ស្រប ពេលដែលពិធីបុណ្យចូលឆ្នាំប្រពៃណីចិន បានឈានចូលមកដល់ ប្រជាជននៅប្រទេសចិនមួយចំនួនបានធ្វើ ដំណើរចេញពីប្រទេសរបស់ខ្លួន ទៅកាន់ប្រទេសនានានៅជុំវិញពិភពលោក។ នៅក្នុងនោះក៏មាន ប្រទេសកម្ពុជាផងដែរ ដែលបានទទួលអ្នកដំណើរពីខេត្តវ៉ូហាន(Wuhan) នៃប្រទេសចិន ដែលជាតំបន់ ផ្ទុះឡើងដំបូងគេបង្អស់នូវជំងឺកូរូណា ឬកូវីដ១៩ ដែលមានតួលេខអ្នកដំណើរមកកាន់ប្រទេសកម្ពុជា សរុបប្រមាណ ៣ពាន់នាក់ជាង[1]។ នៅក្នុងកំឡុងពេលរីករាលដាននៃជំងឺកូវីដ១៩ ប្រជាពលរដ្ឋក៏ដូចជាអ្នក សារព័ត៌មានជាច្រើនបាន ចែករំលែកនូវព័ត៌មានអំពីការរីករាលដាលនៃជំងឺនេះ បើគិតចាប់តាំងពីដើមឆ្នាំ ២០២០ រហូតមកដល់ ខែមិថុនា ឆ្នាំ២០២០ មានការឃាត់ខ្លួន និងការចាប់ខ្លួនព្រមទាំងមានការបិទប្រព័ន្ធ ផ្សព្វផ្សាយមួយចំនួនដូចជាវិទ្យុ គេហទំព័រហ្វេសប៊ុកជាច្រើនទៀត ដោយក្រសួងព័ត៌មានបានលើកឡើងនូវ មូលហេតុថា ប្រព័ន្ធផ្សព្វផ្សាយទាំងអស់នោះ បានធ្វើការផ្សព្វផ្សាយរំលោភបំពានលើវិជ្ជាជីវៈ រហូតឈាន ទៅដល់ការឃាត់ខ្លួន និងចោទពីបទ "ញុះញង់ឱ្យកើតមានអំពើហិង្សា បង្កការរើសអើងពូជសាសន៍ និង ចលាចលសង្គម" យោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា ៤៩៥។

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៤១ ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការ បញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់ កិត្តិយសរបស់អ្នកដទៃ ដល់ ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់ សន្តិសុខជាតិបានឡើយ។ របប សារព័ត៌មានត្រូវបានរៀបចំឡើងដោយច្បាប់[2]។

នៅក្នុងច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥ មាត្រា៤ ការបោះពុម្ពផ្សាយនូវព័ត៌មានផ្លូវការដូចជា សេចក្តីថ្លែងការណ៍ ការប្រជុំ កំណត់ហេតុប្រជុំ ឬរបាយការណ៍ណាមួយ។ល។ មិនអាចត្រូវផ្តន្ទាទោស បានឡើយ ប្រសិនបើការផ្សាយនោះមានលក្ខណៈសមស្របតាមសភាពពិតពេញលេញ ឬសេចក្តីសង្ខេប ត្រឹមត្រូវតាមរឿងពិត[3]។

[1] https://www.bangkokpost.com/world/1846319/more-than-3-000-chinese-from-virus-hit-wuhan-visit-cambodia

[2] រដ្ឋធម្មនុញ្ញ មាត្រា៤១ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ដែលនាពេលឆ្នាំ២០០៨ បានធ្វើវិសោធនកម្មថ្មី ចែងថា ប្រជាពលរដ្ឋខ្មែរ មានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភ នាំឱ្យប៉ះពាល់ដល់កត្តិយសរបស់អ្នកដទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ។ របបសារព័ត៌មានត្រូវបានរៀបចំឡើងដោយច្បាប់។

[3] ច្បាប់ស្តីពីរបបសារព័ត៌មានឆ្នាំ១៩៩៥

ក្រមព្រហ្មទណ្ឌ មាត្រា ៤៩៤ លក្ខខណ្ឌអត្ថិភាពនៃការញុះញង់

ដើម្បីអនុវត្តផ្នែកនេះ ការញុះញង់អាចត្រូវផ្តន្ទាទោស កាលបើអំពើនេះត្រូវបានប្រព្រឹត្តិ:

1. ដោយសំដីតាមប្រភេទណាក៏ដោយ ដែលប្រកាសនៅក្នុងទីកន្លែងសាធារណៈឬនៅក្នុងពេលប្រជុំជាសាធារណៈ។
2. ដោយសំណេរ ឬគំនូរ តាមប្រភេទណាក៏ដោយ ដែលត្រូវផ្សព្វផ្សាយនៅក្នុងចំណោមសាធារណជន ឬតាំងឱ្យសាធារណជនមើល។
3. ដោយគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍សម្រាប់សាធារណជន[4]។

យោងទៅតាមក្រសួងសុខាភិបាល និងនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង បានឱ្យដឹងថាប្រទេសកម្ពុជាបានរកឃើញករណីជំងឺកូវីដ១៩ តាំងពីថ្ងៃទី ២៧ ខែមករា ឆ្នាំ២០២០។




គិតដល់ថ្ងៃទី១៦ ខែមិថុនា ប្រទេសកម្ពុជាបានរកឃើញការកើនឡើងនៃអ្នកឆ្លងជំងឺកូវីដ១៩ ចំនួន ១២៨នាក់ បរទេសចំនួន៧១នាក់ និងខ្មែរចំនួន៥៧នាក់ បុរស៨៩ នាក់ស្មើនឹង៧០% និងស្រ្តី៣៩នាក់ស្មើនឹង៣០%[5]។ បន្ទាប់ពីនោះក៏មានការបិទស្ថាប័នសារព័ត៌មាន និងមានការចាប់ខ្លួនអ្នកសារព័ត៌មានមួយចំនួនដែលទាក់ទងនឹងការចេញផ្សាយព័ត៌មានផ្សេងៗ។

[4] ច្បាប់ស្តីពីក្រមព្រហ្មទណ្ឌ

[5] https://www.facebook.com/MinistryofHealthofCambodia/photos/a.930887636950343/3094616967244055/?type=3&theater ហ្វេសប៊ុកផេក ក្រសួងសុខាភិបាល

គម្រោងប្រព័ន្ធផ្សព្វផ្សាយដើម្បីសន្តិភាពបានរៀបចំធ្វើការស្ទង់មតិមួយ ចាប់តាំងពីខែមករា ឆ្នាំ ២០២០ រហូតមកដល់ថ្ងៃ១៦ ខែមិថុនា ឆ្នាំ២០២០ ដើម្បីឆ្លើយតបទៅនឹងការងារមួយចំនួននៅក្នុងដំណើរការនៃការរីករាលដាលជំងឺកូវីដ១៩ ដូច្នេះហើយបុគ្គលិកគម្រោងក៏បានផ្តួចផ្តើមបង្កើតនូវប្រធានបទស្តីពី "**ស្ថានភាព និងផលប៉ះពាល់ នៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាក្នុងកំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩**" បន្ទាប់ពីការសម្ភាស និងការប្រមូលនូវរឿងរ៉ាវមួយចំនួន យើងទទួលបាននូវលទ្ធផលដូចខាងក្រោម។

## □□. លទ្ធផលដែលបានប្រមូលពីប្រភពផ្តល់ព័ត៌មាន

### ១. ចំនួនអ្នកចូលរួមផ្តល់បទសម្ភាស

ទិន្នន័យនេះបានបង្ហាញចំនួនអ្នកដែលចូលរួមផ្តល់បទសម្ភាស ទាំង២ភេទ សរុបចំនួន ៧១នាក់ (បុរស៤០នាក់ ស្ត្រី៣១នាក់)។




### ២. តួនាទីអ្នកដែលបានផ្តល់បទសម្ភាស

យោងទៅតាមក្រាហ្វិច តួនាទីអ្នកដែលបានផ្តល់បទសម្ភាសបានបង្ហាញថា មន្ត្រីរាជការមាន ៨.៤៥% សិស្សនិស្សិត១៩.៧២% បុគ្គលិកអង្គការសង្គមស៊ីវិល១៩.៧២% គ្រូបង្រៀន១៥.៤៩% បុគ្គលិកក្រុមហ៊ុន២២.៥៤% អាជីវករ១១.២៧% និងចុងក្រោយអ្នកសារព័ត៌មាន ២.៨២% [6]។

[6] **សូមបញ្ជាក់** ក្នុងចំណោមអ្នកផ្តលបទសម្ភាស៧១នាក់ មានអ្នកសារព័ត៌មានចំនួន៩៥នាក់ បានផ្តល់បទសម្ភាសដោយមិនហ៊ានបង្ហាញអំពីតួនាទីពិតប្រាកដ មូលហេតុដើម្បីរក្សានូវសុវត្ថិភាព។ ដូច្នេះហើយទើបធ្វើឱ្យការស្ទង់មតិរបស់យើង មានការបង្ហាញពីតួនាទីអ្នកសារព័ត៌មាន២.៨២% ។




## ៣. ចំនួនអ្នកតាមដានព័ត៌មាន

យោងទៅតាមទិន្នន័យបានបង្ហាញថា អ្នកដែលចូលចិត្តតាមដានព័ត៌មាននៅក្នុងឆ្នាំ២០២០ អ្នកចូលចិត្តមានចំនួន៨០.៣០% និងអ្នកតាមដានម្តងម្កាល១៩.៧០%។



## ៤. ប្រភេទព័ត៌មានដែលចូលចិត្តតាមដាន

យោងទៅតាមទិន្នន័យបានបង្ហាញថា ប្រភេទព័ត៌មានដែលអ្នកផ្តល់បទសម្ភាសចូលចិត្តតាមដានមានដូចជា ព័ត៌មានសង្គម/នយោបាយ៤៧.៧៩% ព័ត៌មានទាន់ហេតុការណ៍២៧.៩៤% ព័ត៌មានសិល្បៈកំសាន្ត១៣.២៤% និងព័ត៌មានកីឡា១១.០៣%។ នោះមានន័យថាព័ត៌មានសង្គម/នយោបាយ ទទួលបានការតាមដានច្រើនជាងគេ។




## ៥. ប្រភេទផ្តល់ព័ត៌មានដែលទទួលបានការតាមដានច្រើន

យោងទៅតាមទិន្នន័យបានបង្ហាញថា ប្រភេទផ្តល់ព័ត៌មានដែលចូលចិត្តតាមដានជាងគេ គឺមានហ្វេសប៊ុក៩៥.៧៧% យូធូប៤៥.០៧% ទូរទស្សន៍៣០.៩៩% កាសែត១៩.៧២% ទស្សនាវដ្តី២.៨២% វិទ្យុ២៥.៣៥% គេហទំព័រ៤៣.៦៦% និងទ្វីតធឺ៧.០៤%។ មានន័យថា ប្រភេទផ្តល់ព័ត៌មានដែលទទួលបានការតាមដានច្រើនជាងគេគឺ ហ្វេសប៊ុក។



## ៦. ប្រព័ន្ធផ្សព្វផ្សាយដែលទទួលបានការគាំទ្រច្រើន

យោងទៅតាមទិន្នន័យបានបង្ហាញថា ប្រព័ន្ធផ្សព្វផ្សាយដែលទទួលបានការគាំទ្រច្រើនជាងគេ គឺមាន ហ្វេសប៊ុក៦៦.២០% យូធូប៩.៨៦% ទូរទស្សន៍១.៤១% ការសែត១.៤១% វិទ្យុ៩.៨៦% គេហទំព័រ ៩.៨៦% និងអិនស្តាក្រាម១.៤១%។




## ៧. ប្រភពផ្តល់ព័ត៌មានដែលជឿទុកចិត្ត

យោងទៅតាមទិន្នន័យបានបង្ហាញថា ប្រភពផ្តល់ព័ត៌មានដែលអាចជឿទុកចិត្តបាន មានដូចជា ប្រព័ន្ធផ្សព្វផ្សាយសង្គមមានចំនួន៦៣.៣៨% ទូរទស្សន៍មានចំនួន២៨.១៦% វិទ្យុមានចំនួន៣០.៩៩% ការសែតមានចំនួន២៦.៧៦% ទស្សនាវដ្តីមានចំនួន២.៨២% និងគេហទំព័រមានចំនួន៣៨.០៣%។



## ៨. ការជឿទុកចិត្តនៅលើប្រព័ន្ធផ្សព្វផ្សាយ

យោងទៅតាមទិន្នន័យបានបង្ហាញថា ប្រព័ន្ធផ្សព្វផ្សាយនាពេលបច្ចុប្បន្នមានភាពជឿទុកចិត្តចន្លោះពី១%ទៅ២០% មានចំនួន៤.២៣% ចន្លោះពី២១%ទៅ៤០% មានចំនួន២១.១៣% ចន្លោះពី៤១%ទៅ៦០%មានចំនួន៥៤.៩៣% ចន្លោះពី៦១%ទៅ៨០%មានចំនួន១៦.៩០% និងចន្លោះពី៨១%ទៅ១០០%មានចំនួន២.៨២%។ បើយោងទៅតាមទិន្នន័យមានន័យថា ការជឿទុកចិត្តរបស់អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយមានចំនួន៥៤.៩៣% ដែលជាចន្លោះរវាង៤១%ទៅ៦០%នៃការជឿទុកចិត្ត។




## ៩. បញ្ហាប្រឈមរបស់ប្រព័ន្ធផ្សព្វផ្សាយ

កំឡុងពេលនៃការរីករាលដាលនៃជំងឺកូវីដ១៩ អគ្គស្នងការដ្ឋាននគរបាលជាតិបានឲ្យដឹងថា មានមនុស្សចំនួន ៩ នាក់ត្រូវបានបញ្ជូនទៅតុលាការពាក់ព័ន្ធនឹងការចែករំលែកព័ត៌មានមិនពិតជុំវិញករណីជំងឺកូវីដ១៩។

អង្គការសិទ្ធិមនុស្សលីកាដូបានលើកឡើងថា មានមនុស្សចំនួន ១៩ នាក់ ត្រូវបានអាជ្ញាធរចាប់ឃាត់ខ្លួនហើយ ១៣ នាក់ ត្រូវបានដោះលែងវិញពាក់ព័ន្ធនឹងជំងឺកូវីដ១៩ដែលកំពុងតែមានការរីករាលដាលនេះ[7]។

[7] Link

យោងទៅតាមអង្គការឃ្លាំមើលសិទ្ធិមនុស្ស ចាប់ពីខែមករា ដល់ខែមិថុនា ឆ្នាំ២០២០ អាជ្ញាធរបានឃុំខ្លួនមនុស្សចំនួន ៣០នាក់ ដោយផ្អែកលើការចោទប្រកាន់ថា ពួកគេបានផ្សព្វផ្សាយព័ត៌មានក្លែងក្លាយអំពីមេរោគកូវីដ១៩នៅកម្ពុជា និងមនុស្សចំនួន ៨០នាក់ ផ្សេងទៀតត្រូវបានដោះលេងឱ្យនៅក្រៅឃុំ[8]។

ក្រសួងព័ត៌មាន បានបង្ហាញឱ្យឃើញថាប្រព័ន្ធផ្សព្វផ្សាយមួយចំនួនត្រូវបានលុបចោលអាជ្ញាបណ្ណនឹងគេហទំព័រមួយចំនួន នៅក្នុងកំឡុងពេលនៃការរីករាលដាននៃជំងឺកូវីដ១៩។ បើយើងក្រឡេកទៅមើលទិន្នន័យដែលបានសម្ភាស និងប្រមូលពីអ្នកសារព័ត៌មាននិងអ្នកសារព័ត៌មានប្រជាពលរដ្ឋបានបង្ហាញដូចខាងក្រោម។

យោងទៅតាមទិន្នន័យបានបង្ហាញថា ប្រព័ន្ធផ្សព្វផ្សាយនាពេលបច្ចុប្បន្នមានបញ្ហាប្រឈមដូចជាមានការរឹតត្បិតលើសេរីភាពបញ្ចេញមតិមានចំនួន៧៧.៤៦% មានការចាប់ខ្លួនអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយចំនួន៥៩.១៥% មានការកំរាមកំហែងចំនួន៥៩.១៥% មានការរឹតត្បិតការចេញផ្សាយចំនួន៤៣.៦៦% មានការបិទនៅប្រព័ន្ធផ្សព្វផ្សាយមានចំនួន៥០.៧០% ការរឹតបណ្តឹងការអនុវត្តសិទ្ធិសារព័ត៌មានចំនួន៤៣.៦៦% ខ្វះការទទួលខុសត្រូវរបស់ក្រសួងព័ត៌មានចំនួន ១.៤១% អ្នកដែលមិនដឹងមានចំនួន៤.២៣% និងមិនគោរពតាមក្រមសីលធម៌វិជ្ជាជីវៈ១.៤១%។




8 https://www.hrw.org/news/2020/06/17/cambodia-end-crackdown-opposition

## ១០. បញ្ហាប្រឈមរបស់អ្នកសារព័ត៌មាន

ក្រសួងព័ត៌មាន បានបង្ហាញឱ្យឃើញថាអ្នកសារព័ត៌មានមួយចំនួនត្រូវបានលុបចោលនូវអាជ្ញាបណ្ណ និងមានការបិទនៅស្ថាប័នព័ត៌មានផ្សេងៗតាមអនឡាញជាដើម។

អគ្គស្នងការដ្ឋាននគរបាលជាតិបានបង្ហាញឱ្យឃើញថា មានការឃាត់ខ្លួននិងចាប់ខ្លួនអ្នកសារព័ត៌មាន និងអ្នកសារព័ត៌មានប្រជាពលរដ្ឋ បន្ទាប់មកឃើញថាមានការដោះលែងវិញមួយចំនួន ក៏ប៉ុន្តែនៅតែមានអ្នកសារព័ត៌មានមួយចំនួនត្រូវបានបញ្ជូនទៅកាន់តុលាការ[9]។

យោងទៅតាមអង្គការលីកាដូបានលើកឡើងថានៅដើមឆ្នាំ២០២០នេះ យ៉ាងតិចណាស់មានអ្នកសារព័ត៌មានជាង១០នាក់ ត្រូវបានកោះហៅ និងសាកសួរដោយនគរបាល និងមន្ត្រីយុត្តិធម៌ ដោយសារការរាយការណ៍ព័ត៌មានរបស់ពួកគាត់។ ការបន្តចាប់ខ្លួន ឃុំខ្លួន និងការធ្វើទុក្ខបុកម្នេញផ្លូវច្បាប់ ចំពោះអ្នកសារព័ត៌មាន ដែលហ៊ានផ្សាយព័ត៌មានរិះគន់ គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរចំពោះសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋកម្ពុជា។ យើងមើលឃើញថាអង្គការសង្គមស៊ីវិលជាច្រើនបានចូលរួមគ្នា ចេញនូវសេចក្តីថ្លែងការរួម «**សូមស្នើសុំដោយទទូចឱ្យរាជរដ្ឋាភិបាល ទម្លាក់ចោលការចោទប្រកាន់ទាំងអស់ចំពោះអ្នកសារព័ត៌មានទាំងនេះ និងសូមឱ្យបញ្ឈប់ការបង្ក្រាបចុងក្រោយនេះទៅលើសេរីភាពសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា**»[10]។

យោងទៅតាមទិន្នន័យបានបង្ហាញថា អ្នកសារព័ត៌មានមានបញ្ហាប្រឈមដូចជា អសុវត្ថិភាពផ្ទាល់ខ្លួន៧០.៤២% ការរារាំងមិនឱ្យទៅយកព័ត៌មាន៤៧.៨៩% ការគំរាមកំហែង៤៩.៣០% ការព្រួយបារម្ភចំពោះការឃាត់ខ្លួន៥៦.៣៤% មានសំពាធពីស្ថាប័ន៥២.១១% មានសំពាធពីមជ្ឈដ្ឋាននានា(សេដ្ឋកិច្ច, អ្នកមាន,នយោបាយ)មានចំនួន៦១.៩៧% និងអ្នកដែលឆ្លើយថាមិនដឹងចំនួន ៤.២៣%។

[9] https://thmeythmey.com/?page=detail&id=90444

[10] https://www.licadho-cambodia.org/pressrelease.php?perm=452&khmer




## ១១. ប្រព័ន្ធផ្សព្វផ្សាយសង្គមរងផលប៉ះពាល់ និងអ្នកសារព័ត៌មានមានការរិតត្បិត

**ករណីសិក្សាទី១៖** លោក **កួយ សំអាត** អាយុ៣៥ឆ្នាំ រស់នៅភូមិព្រែកតាគង់ សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានមុខរបរជាអ្នកលក់ Online និងជាអ្នកជល់មាន់។ ដោយលោក បានបង្ហោះវីដេអូឃ្លីបមួយនៅលើហ្វេសប៊ុកដែលមានឈ្មោះ "Tep Visal" ដោយបានសរសេរថា "**បងប្អូនគួរតែអគុណយួន កុំតែយួនស្រែកថាកម្ពុជាមានកូវីដ១៩ កំអីបងប្អូនអត់ដឹងទេ នេះសំណាងហើយយួនស្រែក បើប្រជាជនខ្មែរស្រែក ប្រហែលតាមចាប់ទៀតហើយ**" បន្ទាប់ពីលោកបានបង្ហោះនៅការសម្តែងមតិនោះមក សមត្ថកិច្ចបានចាត់ទុកថាការសម្តែងមតិរបស់គាត់ ជាករណីញុះញង់ឱ្យប្រព្រឹត្តិបទល្មើសជាអាទិ៍ មានការចាប់ខ្លួននៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ការចោទនេះផ្អែកពីច្បាប់ស្តីពីរបបសារព័ត៌មាន និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[11]។

**ករណីសិក្សាទី២៖** កញ្ញា **ថៃ ឆយឿន** រស់នៅភូមិជ្រៃ ឃុំកណ្តែក ស្រុកប្រាសាទបាគង់ ខេត្តសៀមរាប កញ្ញាបានបង្ហោះព័ត៌មានមួយថា "**អ្នកព្រៃគុយមួយគ្រួសារឆ្លងវីរុសក្សូណា( ហើយមានកូនគាត់រៀននៅសាលាស្វាយធំ សូមប្រយ័ត្នទាំងអស់គ្នាផងណា ព្រោះពួកគាត់មិនដឹងបានដើរចម្លងអ្នកណាខ្លះទេ )**" ក្រោយពីការបង្ហោះសារនោះរួចមក សមត្ថកិច្ចបានចុះទៅធ្វើការឃាត់ខ្លួននៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ សមត្ថកិច្ចបានធ្វើការអប់រំណែនាំ និងធ្វើកិច្ចសន្យាមុននឹងដោះលែងឱ្យត្រលប់មកផ្ទះវិញ[12]។

**ករណីសិក្សាទី៣៖** កញ្ញា **ន.យ.ម** មានអាយុ១៤ ឆ្នាំ រស់នៅភូមិកោះគ្រឹស្នា ឃុំឬស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត បច្ចុប្បន្នជាសិស្សសាលាចិនមួយនៅខេត្តកំពត។ **កញ្ញា** បានផ្សាយព័ត៌មានតាម Messengers ថា "**មានសិស្សសាលាភាសាចិនមួយក្នុងខេត្តកំពត មានឆ្លងវីរុសកូវីដ១៩ ចំនួន០៣នាក់ និង**

[11] https://tvfb.news/article/32399?fbclid=IwAR0qwFYorrHWbNQUFv-dE0EY5qNZnSQheXZdixE62ovCYKAS2eY9cG_5RsE
[12] Link

**មានមនុស្សស្លាប់ចំនួន០៣នាក់ ស្ថិតនៅក្នុងខេត្តកំពត**" បន្ទាប់ពីការផ្ញើសារនេះរួច ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួននៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០[13]។

**ករណីសិក្សាទី៤៖** លោក **សុវណ្ណរិទ្ធី** ជានិពន្ធនាយករបស់TVFB Online បច្ចុប្បន្នរស់នៅក្នុងបុរីពិភពថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។ បន្ទាប់ពីនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានធ្វើសន្និសិទ្ធិការសែតនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០២០ លោកបានលើកឡើងនូវពាក្យមួយចំនួនដូចជា "**បើអ្នករត់ម៉ូតូឌុបក្ស័យធន លក់ម៉ូតូចាយសិនទៅ រដ្ឋាភិបាលគ្មានលទ្ធភាពជួយនោះទេ**" កាលពីយប់ថ្ងៃទី០៧ដដែលលោក សុវណ្ណរិទ្ធី បានស្រង់ចំណុចមួយដែលថា "**បើអ្នករត់ ម៉ូតូឌុបក្ស័យធន លក់ម៉ូតូចាយសិនទៅ រដ្ឋាភិបាលគ្មានលទ្ធភាពជួយនោះទេ**" បន្ទាប់ពីបានបង្ហោះសារនៅលើផេករបស់គាត់មក ត្រូវបានសមត្ថកិច្ចធ្វើការឃាត់ខ្លួននៅថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ និងចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទល្មើសជាអាទិ៍ តាមមាត្រ៤៩៥ នៃក្រមព្រហ្មទណ្ឌ[14]។

**ករណីសិក្សាទី៥៖** លោក **សុខ ឧត្តម** ជាម្ចាស់គេហទំព័រ **រិទ្ធិសែន និងស្ថានីយវិទ្យុ** □□ 99.75□□□ ត្រូវបានក្រសួងព័ត៌មានសម្រេចលុបចោលអាជ្ញាបណ្ណ ក្រោមការចោទថា គេហទំព័ររបស់លោកបានផ្សព្វផ្សាយព័ត៌មានបំផ្លើសការពិត ញុះញង់ឱ្យកើតមានអំពើហិង្សា បង្កការរើសអើងពូជសាសន៍បង្កអសន្តិសុខ និងចលាចលក្នុងសង្គមដែលជាការរំលោភបំពាន លើវិជ្ជាជីវៈ[15]។

**ករណីសិក្សាទី៦៖** ព្រះតេជគុណ **កើត សារ៉ាយ** និងសកម្មជនផ្សេងទៀតចំនួន១៤នាក់ នៅខេត្តបាត់ដំបង បានធ្វើកូដកម្មបង្អត់អាហារ និងធម្មយាត្រាដោយសន្តិវិធី នៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០២០ បានធ្វើការទាមទារឱ្យរដ្ឋាភិបាលជួយធ្វើការអន្តរាគមន៍ទៅស្ថាប័ន មីក្រូហិរញ្ញវត្ថុ និងធានាគារ ឱ្យពន្យាពេលសងប្រាក់បំណុលធានាគារដល់ប្រជាពលរដ្ឋ ដែលជួបវិបត្តិដោយសារការរាតត្បាតជំងឺកូវីដ១៩។ បន្ទាប់មកមានអាជ្ញាធរខេត្ត នាំកម្លាំងប៉ូលីស និងប៉េអិម មកស្ទាក់ជាប់មុំអាគារមីក្រូហិរញ្ញវត្ថុប្រាសាក់នៅកណ្តាលទីរួមខេត្តបាត់ដំបង ដើម្បីយកទៅធ្វើកិច្ចសន្យា និងផ្តិតមេដៃ កុំធ្វើអ្វីដែលប៉ះពាល់ដល់សណ្តាប់ធ្នាប់សង្គម។ ការឃាត់ខ្លួនយកមកធ្វើកិច្ចសន្យានេះ ជាការរំលោភសិទ្ធិសេរីភាពនៃការប្រមូលផ្តុំដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ មាត្រា ៣៥ "ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ជាតិ។ សេចក្តីស្នើសុំទាំងឡាយរបស់ប្រជាពលរដ្ឋត្រូវបានទទួលការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ ពីអង្គការរដ្ឋហើយច្បាប់ក៏បើកផ្លូវឱ្យពលរដ្ឋអាចប្រមូលផ្តុំ ឬធ្វើបាតុកម្មដោយសន្តិវិធីផងដែរ"[16]។

13 http://kampucheathmey.com/2016/covid-19-catch/?fbclid=IwAR26qpGtRX-lQtzn0rPa1jHjuoi6l6o8tqKgCJ4evNDcxWyt7eeBMkCCrE4
14 https://thmeythmey.com/?page=detail&id=90444
15 https://khmernote.com.kh/news/88190
16 Link ចុះផ្សាយដោយ យន មៀន ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២០ នៅ វិទ្យុអាស៊ីសេរី

**ករណីសិក្សាទី៧៖** អ្នកស្រី **ចក់ សូត** កម្មការិនីរោងចក្រកាត់ដេរសម្លៀកបំពាក់ QuantumClothing ដែលស្ថិតនៅតំបន់វេងស្រេងជាយក្រុងភ្នំពេញ ត្រូវបានព្យួរការងារនៅ ថ្ងៃទី៣០ ខែមីនា នេះដោយសាររោងចក្ររងផលប៉ះពាល់ពីការផ្អាកបញ្ជាទិញពីបរទេស កំឡុងពេល ការីករាលដាលនៃជំងឺកូវីដ១៩ អ្នកស្រីបានបន្ថែមថា ការទទួលបាន ៤០ភាគរយនៃប្រាក់ឈ្នួលអប្បបរមារយៈពេលពីរខែ នៃការអត់មានការងារធ្វើ ហើយក្នុងនោះមាន ២០ភាគរយដែល រដ្ឋាភិបាលសន្យាថានឹងផ្ដល់ឲ្យពេលព្យួរការងារ អ្នកស្រីមិនទាន់បានទទួលនៅឡើយទេ។ អ្នកស្រីបានលើកឡើងអំពីការព្រួយបារម្ភណ៍ថា «**ខ្ញុំអ្នកទីទាល់ក្រអីចឹង ហើយដូចថាខ្ញុំជាប់ធនាគាររាប់ម៉ឺន(ជាងមួយម៉ឺនដុល្លារ) អីចឹង ខ្ញុំបារម្ភ។ បើសិនជារោងចក្រហ្នឹងបិទ អាចខាងធនាគារគេរឹបអូសយកដី យកផ្ទះរបស់ខ្ញុំអីចឹង។ ខ្ញុំបារម្ភខ្លាំងដែរហ្នឹង!**»[17]។

**ករណីសិក្សារទី៨៖** លោក **កែវ ភន់** ជាកម្មករធ្វើការនៅរោងចក្រកៅវ៉េ (Kaoway) ត្រូវបានថៅកែបញ្ឈប់ពីការងារ ក្រោយពេលលោកផ្ដល់បទសំភាសជាមួយវិទ្យុអាស៊ីសេរី កាលពីថ្ងៃទី៣០ ខែមីនា លោកបានបញ្ចេញមតិថា "រោងចក្រមួយនេះ មិនសូវគិតគូរដល់សុខភាព និងសុវត្ថិភាពកម្មករ ពាក់ព័ន្ធនឹងការរាតត្បាតជំងឺកូវីដ-១៩"[18]។

## សេចក្តីសន្និដ្ឋាន

ប្រព័ន្ធផ្សព្វផ្សាយនិងអ្នកសារព័ត៌មានមានតួនាទីសំខាន់ ក្នុងការចូលរួមចំណែកផ្សព្វផ្សាយ ការពារ និងទប់ស្កាត់នៅជំងឺកូវីដ១៩ និងមានកត្តាដ៏សំខាន់នៅក្នុងការចែករំលែកព័ត៌មានអំពីជំងឺកូវីដ១៩ និងព័ត៌មានផ្សេងទៀតដែលកើតមានឡើងនៅក្នុងសង្គម។ កាលណាបើប្រទេសមួយមិនមានប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និងប្រព័ន្ធផ្សព្វផ្សាយដែលផ្សព្វផ្សាយព័ត៌មានប្រកបដោយភាពត្រឹមត្រូវ តម្លាភាព និងគោរពនូវក្រមសីលធម៌នៃវិជ្ជាជីវៈសារព័ត៌មាន។ ប្រព័ន្ធផ្សព្វផ្សាយមានតួនាទីយ៉ាងសំខាន់ក្នុងការចែករំលែកនូវព័ត៌មានពិត និងព្រឹត្តិការណ៍ដែលបានកើតឡើងនៅក្នុងសង្គមជូនទៅដល់សាធារណៈជនទូទៅបានដឹងនិងបានជ្រាប។

តាមរយៈការស្រាវជ្រាវខាងលើបានបង្ហាញថា ការអនុវត្តច្បាប់មួយចំនួនផ្ទុយពីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា៣៥ និងមាត្រា៤១។ ស្ថាប័នព័ត៌មាននិងអ្នកសារព័ត៌មានព្រមទាំងអ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម នៅតែមានការព្រួយបារម្ភណ៍ចំពោះសេរីភាពក្នុងការបញ្ចេញមតិ។ ទន្ទឹមនឹងនេះដែរ ឃើញថាមានប្រព័ន្ធផ្សព្វផ្សាយមួយចំនួនត្រូវបានបិទ និងស្ថាប័នព័ត៌មានមួយចំនួនត្រូវបានក្រសួងព័ត៌មានលុបចោលអាជ្ញាបណ្ណ លើសពីនេះផងមានអ្នកសារព័ត៌មានមួយចំនួនត្រូវបានចាប់ខ្លួន ព្រមទាំងមានការ

[17] Link
[18] Link

ចោទប្រកាន់ពីបទ ញុះញង់ តាមក្រមព្រហ្មទណ្ឌ មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌ។ ដូចនេះហើយដើម្បីចូលរួមកាត់បន្ថយនូវ ការរឹតត្បិតសិទ្ធិសេរីភាពសារព័ត៌មាន អ្នកផ្តល់សម្ភាស បានផ្តល់នូវអនុសាសន៍ និងសំណូមពរ ដើម្បីឱ្យមានការផ្តល់នូវព័ត៌មានត្រឹមត្រូវ និងគោរពសិទ្ធិសារព័ត៌មាន គោរពសិទ្ធិក្នុងការសម្តែងមតិជាដើម។

## អនុសាសន៍ និងសំណូមពរ

- រដ្ឋាភិបាលគួរតែផ្តល់នៅសិទ្ធិនិងសេរីភាពពេលលេញក្នុងការបញ្ចេញមតិរបស់ប្រជាពលរដ្ឋ និងអ្នកសារព័ត៌មាន ព្រមទាំងភាគីពាក់ព័ន្ធ។
- រដ្ឋាភិបាលគួរតែគាំទ្រដល់អ្នកសារព័ត៌មានដែលមានការចេញផ្សាយនៅព័ត៌មានពិតនិងប្រកបដោយវិជ្ជាជីវៈ។
- រដ្ឋាភិបាលគួរតែផ្តល់សិទ្ធិពេញលេញ និងឯករាជ្យភាពដល់អ្នកសារព័ត៌មានក៏ដូចជា ស្ថាប័នសារព័ត៌មាន។
- អ្នកសារព័ត៌មាន ត្រូវរិះរកមធ្យោបាយដើម្បីស្វែងរកប្រភព និងសរសេរព័ត៌មានដែលមាននៅចំណុចទាំងអស់ខាងក្រោម៖
    - ការផ្សាយព័ត៌មានដែលកើតមានពិត និងមិនលំអៀង
    - ការផ្សាយព័ត៌មានទៅតាមដំណាក់កាល នៃជំងឺកូវីដ១៩
    - ការផ្សាយព័ត៌មានដែលមានការផ្សះផ្សា និងដោះស្រាយទំនាស់
    - ការផ្តល់ព័ត៌មានដែលមិនមាននិន្នាការនយោបាយ ឬបុគ្គលណាមួយ
    - គោរពក្រមសីលធម៌អ្នកសារព័ត៌មាន ច្បាប់ស្តីពីរបបសារព័ត៌មាន និងគោរពទៅតាមគោលការណ៍របស់ក្រសួងសុខាភិបាលក្នុងកំឡុងពេលកូវីដ១៩
- អ្នកប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទាំងអស់ ត្រូវមានក្រមសីលធម៌ក្នុងការចែករំលែកសារ ការបញ្ចេញទស្សនៈ ដែលទាក់ទងទៅនឹងនយោបាយ។ មិនត្រូវប្រើប្រាស់បណ្តាញសង្គមជាឧបករណ៍ក្នុងការវាយប្រហាគ្នាទៅវិញទៅមកនោះទេ។ ប្រសិនបើជាការរិះគន់ត្រូវរិះគន់បែបស្ថាបនា ហើយការចែករំលែកត្រូវគោរពទៅតាមចំណុចមួយចំនួនដូចខាងក្រោម៖
    - ចែករំលែកព័ត៌មានដែលកើតមានពិត
    - មានប្រភពច្បាស់លាស់ ទីកន្លែង និងពេលវេលា
    - មិនត្រូវសរសេរព័ត៌មានបែបប្រឌិត
    - ការប្រើប្រាស់ពាក្យពេចន៍មិនសមរម្យ
    - ការប្រើប្រាស់ ឬចែករំលែករូបភាពដោយមិនមានការអនុញ្ញាត

- ស្ថាប័នពាក់ព័ន្ធ និងអង្គការសង្គមស៊ីវិល ត្រូវរួមគ្នាដើម្បីបណ្តុះបណ្តាលពីក្រមសីលធម៌អ្នកសារព័ត៌មានឱ្យបានទូលំទូលាយ ជាពិសេសអត្ថប្រយោជន៍នៃការចូលរួមរបស់អ្នកសារព័ត៌មាន នៅក្នុងកំឡុងពេលរីករាលដាលជំងឺកូវីដ១៩។
- សូមក្រសួងព័ត៌មានធ្វើការត្រួតពិនិត្យមុននិងផ្តល់អាជ្ញាបណ្ណដល់ស្ថាប័នសារព័ត៌មាន និងបង្កើតឱ្យមានវគ្គបណ្តុះបណ្តាលក្រមសីលធម៌អ្នកសារព័ត៌មាន និងច្បាប់ស្តីពីរបបសារព័ត៌មានឱ្យបានជាញឹកញាប់។

## ឯកសារយោង

១. រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងវិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ២០០៨

២. ច្បាប់ស្តីពី របបសារព័ត៌មាន ដែលបានអនុម័តនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៩៥ នាសម័យប្រជុំលើកទី០៤ នីតិកាលទី០១

៣. ច្បាប់ស្តីពី ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ សម័យប្រជុំលើកទី៣ នីតិកាលទី៤ ដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំលើកទី៦ នីតិកាលទី២។

៤. ការចេញផ្សាយនៅលើគេហទំព័រផ្លូវការរបស់ក្រសួងសុខាភិបាល

៥. នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង

## The Alliance for Conflict Transformation

Alliance for conflict transformation is a local non-profit, non-political, and non-faith-based organization located in Phnom Penh. ACT is composed of like-minded individuals committed to working together to provide skills and knowledge in conflict resolution and transformation, and peace building. ACT mainly focuses on building and strengthening capacities for peace based on analysis of current issues. These skills include identifying the most strategic actions to transform conflicts, in order to maximize the impact for sustainable peace and development. ACT was registered as an organization in 2002 after carrying out a number of peace building training programs.

## About this Survey

The Survey in Media for Peace Project aims to be used as an additional input to the project and to find any gaps that can be worked on. We also want to know about the the opinions of journalists and citizens regardings media consumption and media preferences or current media trust. The stories and other reports that have been collected will be used as the document for future study of the next generation whilethe opinions of journalists and journalists, citizens and issues that have arisen will keep as the supporting document in order to call for the governement and relevant stakeholders to find appropriate solutions followign the principles of universal peace.

## Acknowledgement

ACT would like to thank all networks in the Media for Peace Peace for sharing ther ideas and prepare the questionnaire. Our thanks also go to all ACT staff for entering data and compiling this report.

ACT hopes that the report on “**The situation and impact of the media in Cambodia during the COVID- 19 outbreak”** is useful for future work and study. ACT is responsible for the contents in this report and it does not reflect the views of donors and other stakeholders.

Finally, We would like to commend and thank the management and staff of the organization, the team for resolving all disputes, which is a source of strength and shared experiences and knowledge on some of the content that made this work even better. ACT wish you all good health and lasting peace.

This survey was funded by Bread of the World (BfdW).

## Feedback

Should you have any questions, feedback or further information about this report please email to ACT at act@act.org.kh

# Content


## About ACT

## About This Survey

## Acknowledgement

**I. Introduction ……………………………………………………………………...1**

**II. Result from online source………………………………………………………..2**

1. Number of interviewees……………………………………………………….2
2. Interviewees' occupation……………………………………………………....3
3. Number of media consumers…………………………………………………..3
4. Media preference……………………………………………………………….4
5. Most followed media source…………………………………………………..4
6. Most support social media……………………………………………………..5
7. Reliable source of information………………………………………………...7
8. Trust on social media…………………………………………………………….8
9. Social media challenges………………………………………………………….9
10. Journalists Challenges………………………………………………………...10
11. Impact of social media on journalists and users……………………………..11

## Conclusion

## Recommendation

## References

# I. Introduction

The virus has risen and became wide spreading Wuhan town, China. At the same time, Chinese New Year was coming and some people in China traveled from their home countries to countries around the world including Cambodia, which received passengers with a total number of 3000 people from Wuhan[1], China where the outbreak of coronavirus or COVID-19 has occured,. During the outbreak of COVID-19 the citizen and journalists share information about widespreadin from early 2020 until June 2020, therehad been arrest and detentions as well as the closure of some media outlets such as radio and facebook pages. whilehe Ministry of Information claimed that those social media outlets were reporting news unprofessionally. It led to arest and detention with the accuse of ’incitement to violence, discrimination and social unrest’according to the Criminal law of the Kingdom of Cambodia, Article 495.

In According to the Constitution of the Kingdom of Cambodia, Article 41 stated that Khmer citizens shall have the freedom to express their personal opinions, the freedom of press, of publication and of assembly. No one can take abusively advantage of these rights to impinge on dignity of others, to affect the good mores and custom of society, public order and national security. The regime of the media shall be regulated by law[2].

The Press Law 1995, Article 4 mentioned that the the publication of official information such as statements, meetings, meeting minutes or reports, etc. may not be penalized it such publication is fully true or an accurate summary of the truth[3].

The Criminal Law, article 495 about the Existence of incitement
For the enforcement of this Section, the incitement is punishable when it is committed:

1. By speech of any kind, made in a public place or meeting.
2. By writing or picture of any kind, either displayed or distributed to the public.
3. By any audio-visual communication to the public[4].

According to Ministry of Health and Communicable Disease Control Department (CDCD) show Cambodia find the case of COVID-19 since 27 January 2020.

[1] https://www.bangkokpost.com/world/1846319/more-than-3-000-chinese-from-virus-hit-wuhan-visit-cambodia
[2] Constitution, Article 41 of the Kingdom of Cambodia, 1993
[3] Press law 1995
[4] Criminal law




Since 16 June finds 128 new cases of COVID-19 outbreak in Cambodia, there are 71 foreigners and 57 Cambodians, 89 men equal to 70% and women 39 equal 30%. Following that, the press was shut down and some journalists were arrested in connection with the release of various news items[5].

The Project Media for Peace conducts the survey from January 2020 to 16 June 2020 in response to some of the work in the process of spreading COVID-19 disease.Project staff initiated the theme **"The Situation and Impact of the Media in Cambodia during the COVID-19 outbreak"** after interviewing and collecting some stories. In doing so, we get the following results.

## II. Results from online sources

### 1. Number of interviewees

According to data showed a total of 71 participants (40 men, 31 women).




[5] https://www.facebook.com/MinistryofHealthofCambodia/photos/a.930887636950343/3094616967244055/?type=3&theater

## 2. Interviewees' occupation

According to the pie chart the position of giving interview show Government officer8.45%, student19.72%, CSOs19.72%, Teacher15.49%, Company staff22.54%, Business11.27%, and Journalists2.82%[6].




## 3. Number of Media consumers

According to the pie chart show those who like to follow the news in 2020 likes80.30 and occasional followers 19.70%.




[6] Note: Of the 71 interviewees, 45 were interviewed not dear to reveal their true role and reasons for staying safe. That is why our survey highlights the role of the journalist.

## 4. Media Preference

According to the graphic shows the types of information that the interviewer likes to follow include, Social/Political47.79%, Hotnews27.94%, Entertainment News 13.24%, and sports news11.03%. That means the social/political news gets the most attention.




## 5. Most Followed media source

According to the data the most popular sources of information are Facebook95.77%, Youtube45.07%, Television30.99%, Newspaper19.72%, Magazine2.82%, Radio25.35%, Website43.66%, and Twitter7.04%. The mean most followed source of information is Facebook.



## 6. Most Support Social Media

According to the graphic show the most viewed media sources are Facebook 66.20%, Youtube 9.86%, Television 1.41%, Newspaper 1.41%, Radio 9.86%, Website 9.86%, and Instagram 1.41%.




## 7. Reliable Source of Information

According to the graphic show the reliable sources of information include: Social Media63.38%, Television28.16%, Radio30.99%, Newspaper26.76%, Magazine2.28%, and website38.03%.



## 8. Trust on Social Media

According to the data shows the current media is credible between1%-20% has 54.93%, between21%-40% has 21.13%, between41%-60% has 54.93%, between61%-80% has 16.90%, between81%-100% has 2.82%. The data show Media user trust is 54.93%, which is between41% to 60% of the trust.




## 9. Social Media Challenges

During the outbreak of COVID-19 the National Police show 9 people have arrested sent to court in connection with the sharing of false information surrounding the cases of COVID-19.

LICADHO reports that 19 people have been arrested and 13 have been released in connection with the COVID-19 outbreak[7].

According to Human Rights Watch, from January to June 2020, authorities detained 30 people based on allegations that they spread fake information about COVID-19 virus in Cambodia, and 80 others were released on bail[8].

The Ministry of Information shows that some media outlets have had licenses revoked and some websites during COVID-19 outbreak. If we look at the data interviewed and collected from journalists and citizen journalists, it is shown below.

According to graphic current of social media challenges there are restrictions on freedom of expression77.46%, there have been arrests of media users59.15%, there have been threats to some

[7] Link
[8] https://www.hrw.org/news/2020/06/17/cambodia-end-crackdown-opposition

journalists59.15%, there are restrictions of the press release43.66, Lack of responsibility of the Ministry of Information1.41%, Non-compliance with professional ethics1.41%, and don't know4.23%.




## 10.Journalists Challenges

The Ministry of Information shows that some journalists have had their licenses revoked and closed at various online media outlets.

The General Commission of the National Police revealed that arrests and detentions of journalists and citizen journalists, after that some people released. However, some journalists are still being sent to court[9].

According to LICADHO, at the beginning of 2020, at least 10 journalists were summoned and questioned by police and justice officials because of their reporting. The continued arrest, detention and legal persecution of journalists who dare to publish critical news is a serious violation of the right to information of Cambodians. We see that many civil society organizations have joined together in the joint statement **"Release Imprisoned Journalists and End Media Crackdown"[10].**

According to the graphic shows issue of journalists have Personal insecurity70.42%, Preventing the retrieval of information47.89%, Threats49.30%, There is concern about the detention56.34%, There are institutional pressures52.11%, There is pressure from various backgrounds(Economic,Powerful...) 61.97%, Don't know4.23%.

[9] https://thmeythmey.com/?page=detail&id=90444
[10] https://www.licadho-cambodia.org/pressrelease.php?perm=452&khmer




## 11.Impact of Social Media on Journalists and Users

**Case 1: Mr Koy Somart** 35 years live in the Prektakong village Chakanreler commune Meanchey district Phnom Penh. He is a sell online and fights chicken. He posted a video clip on Facebook called "Tep Visal" write **"You should thank the Vietnamese, if the Vietnamese speak that Cambodia has covid-19, you do not know, this is lucky and Vietnamese speaks, if the Cambodian people speak, maybe they will be an arrest"** after he posted that expression the authorities considered his expression to be a case of incitement to commit a crime, including his arrest on March 9, 2020. This accusation is contrary to the Press Law and the Constitution of the Kingdom of Cambodia[11].

Case 2**: Ms Thai Choryern** live in the Chrey village Orndat commune Brasatbakong district Siem Reap province. She posted news **"A family of Prey Kuy infected with the coronavirus (and their children are studying at Svay Thom school, please be careful because they do not know who they are infecting**)" After posting that message, the police made an arrest on March 9, 2020. Authorities to educated and contracted him, before releasing him to return home[12].

Case 3: **Ms N.Y.M** 14 years live in the Koskresna village Russey srokhanleach commune Kompongtrach district Kampot province. She share message to messengers **"Chinese language**

[11] https://tvfb.news/article/32399?fbclid=IwAR0qwFYorrHWbNQUFv-dE0EY5qNZnSQheXZdixE62ovCYKAS2eY9cG_5RsE
[12] Link

**school student in Kampot province was infected with COVID-19 and 3 died in Kampot province”** After sending this message, she was arrested on March 12, 2020[13].

Case 4: **Mr Sovannrithy** is Editor-in-Chief of TVFB Online currently he lives in Borey Piphub Thmey Sen Sok district Phnom Penh. After the Prime Minister of the Kingdom of Cambodia held a press conference on 07 April 2020, he mentioned in words such as “who said that mototaxi drivers could sell their motorcycles to buy food if they face bankruptcy” After posting a message on his page, he was arrested on 08 April 2020 and charged with incitement to commit a crime under Article 495 of the Penal Code.[14]

Case 5: **Mr Sok Oudom** is the editor website Rithisen and Radio FM99.75MHz the Ministry of Information decides to delete the license, allegedly, his website published fack news, incitement to violence, discriminate, insecurity and social unrest, which is a violation of the professional[15].

Case 6: **Ven Kert Saray** and 14 other activists in Battambang province on 09 May 2020 went on a hunger strike and peaceful pilgrimages urges the government to intervene with microfinance institutions and banks to delay repayment of bank debt to people affected by COVID-19 outbreak. After that, the provincial authorities brought the police and PM forces to ambush the PRASAC MFI building in the middle provincial to make a contract and give a thumbs up, do not do anything that affects social. This contract arrest is a violation of the right to freedom of assembly the Constitution in Article 35 “Khmer citizens of both sexes have the right to participate actively in the political, economic, social and cultural life of the nation. All requests from citizens shall be given full consideration and resolution by the State’s organizations”[16].

Case 7: **Ms Chok Suot** is a factory worker the Quantum Clothing has location Veng Sreng was suspended on 30 March due to the factory affected by the suspension of foreign orders during the outbreak of COVID-19. She speak the receiving 40 percent of the two-month minimum wage of unemployment, of which 20 percent the government has promised to give her, now not yet been paid from the government. She raised concerns that “"I'm poor and I'm debt in a bank of tens of thousands [more than ten thousand dollars], so I'm worried. If the factory closes, the bank will confiscate the land and take my house. I'm very worried!”[17].

---

[13] http://kampucheathmey.com/2016/covid-19-catch/?fbclid=IwAR26qpGtRX-lQtzn0rPa1jHjuoi6l6o8tqKgCJ4evNDcxWyt7eeBMkCCrE4
[14] https://thmeythmey.com/?page=detail&id=90444
[15] https://khmernote.com.kh/news/88190
[16] Link
[17] Link

Case 8: **Mr Keo Phoun** is a factory worker KAOWAY was fired by his employer after giving an interview to Radio Free Asia on 30 March. He was expressions "This factory does not pay much attention to the health and safety of workers involved in the COVID-19 outbreak"[18].

## Conclusion

The media and journalists play an important role in contributing to the prevention and control of COVID-19, sharing information about COVID-19 and other information that occurs in society. If the media is not independent and not transparent and does not respect professional ethics, society will be full of fake news. The media is essential in sharing factual information and events that have taken place in society to the general public.

The above research shows that the application of some laws is contrary to the Constitution of the Kingdom of Cambodia in Articles 35 and 41. Institutions and journalists, as well as social media users, remain concerned about freedom of expression. Meanwhile, some media outlets have been close and some media outlets have had their deleted licenses by the Ministry of Information in addition, a number of journalists were arrested and charged with incitement under Article 495 of the Penal Code. Therefor to contribute to reducing restrictions on press freedom the interviewer provided recommendations and suggestions to provide accurate information and respect the rights of the press, respect for the right to express opinions.

## Recommendation

- The government should provide full rights and freedom of expression of citizens and journalists, as well as stakeholders.
- The government should support journalists who publish news that is fact and professional.
- The government should give full rights and independence to the journalists as well as the media.
- Journalists need to find ways to find sources and write information available at all of the following points:
    - Dissemination of factual information and impartial
    - Dissemination of information on the stages of COVID-19
    - Disclosure of Conciliation and Conflict Resolution
    - Providing information that is not politically or personally biased

[18] Link

  - Respect the ethics of journalists, on the press law and adhere to the principles of the Ministry of Health during COVID-19
- All media users must be ethical in sharing messages, expressing political views. Do not use social media as a tool to attack each other. If it is a recommendation, be constructive and share it accordingly:
  - Share factual news
  - All source place and time
  - Do not write fiction
  - Improper use of words
  - Unauthorized use image or sharing of images
- Relevant institutions and civil society organizations must work together to provide comprehensive training on journalistic ethics, especially the benefits of journalistic participation during the COVID-19 outbreak.
- The Ministry of Information should conduct pre-screening and licensing of media institutions and establish more training courses on journalistic ethics and the law on the media.

## References

1. Constitution in 1993 and Amendments to the 2008 Constitution
2. The Press law, Adopted on 18 July 1995, at the 4th Session of the 1st Legislature
3. Law on the Penal Code, which was approved by the National Assembly on 12 October 2009, the third session of the fourth legislature the Senate fully, approved the form and concept of this law without any amendment on 17 November 2009, at the 6th session of the 2nd legislature.
4. Published on the official website of the Ministry of Health
5. Communicable Disease Control Department (CDCD)

ប្រព័ន្ធផ្សព្វផ្សាយនិងអ្នកសារព័ត៌មានគឺជាជនរងគ្រោះនៃជម្លោះ ប៉ុន្តែពួកគេក៏មានតួនាទីយ៉ាងសកម្មផងដែរនៅក្នុងភាពតានតឹងកាន់តែខ្លាំងឡើងនៅក្នុងសង្គមដែលបែកបាក់គ្នា។

ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាននិងអ្នកសារព័ត៌មានក៏ស្ថិតនៅជួរមុខនៃគំនិតផ្តួចផ្តើមក្នុងការកសាងសន្តិភាព។